*រៀបរៀងដោយ វេជ្ជ.ហេង សៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥*

# វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត (Rabies Vaccine)

## ១- ជំងឺឆ្កែឆ្កួតជាអ្វី?

ជំងឺឆ្កែឆ្កួតគឺជាជំងឺដ៍កាចសាហាវមួយដែលបង្ករោគដោយវីរុសឆ្កែឆ្កួត។

- ជាទូទៅ ជំងឺឆ្កែឆ្កួតឆ្លងរាលដាលក្នុងអំបូរសត្វផ្សេងៗ ហើយក៏អាចចំលងមកមនុស្សបានដែរ តាមរយៈសត្វដែលមានផ្ទុកមេរោគឆ្កែឆ្កួតខាំ។
- នៅក្នុងដំណាក់កាលដំបូងនៃការឆ្លង គេមិនឃើញមានស្តែងចេញនូវរោគសញ្ញាអ្វីឡើយ។ លុះច្រើនសប្តាហ៍ រឺច្រើនខែបន្ទាប់ពីសត្វដែលមានផ្ទុកមេរោគឆ្កែឆ្កួតខាំនោះ ទើបគេឃើញមានស្តែងចេញនូវរោគសញ្ញាឈឺចាប់ អស់កំលាំង ឈឺក្បាល គ្រុនក្តៅ និងមានអារម្មណ៍រញ៉ាំរញ៉ូវ។ បន្ទាប់មក ជំងឺនេះស្តែងចេញជារោគសញ្ញាធ្ងន់ធ្ងរដូចជា ការប្រកាច់ វង្វេងវង្វាន់ ខ្លាចទឹក ខ្លាចខ្យល់ និងភាពខ្វិនកំរើកលែងបាន។ ជំងឺឆ្កែឆ្កួតនៅលើមនុស្សជានិច្ចកាលតែងតែបណ្តាលអោយស្លាប់បាត់បង់ជីវិត។
- ជាញឹកញាប់ សត្វឆ្កែជាប្រភពដែលចំលងជំងឺនេះមកមនុស្ស ក៏ប៉ុន្តែ អំបូរសត្វមួយចំនួនដូចជា ឆ្មា ស្វា ប្រចៀវ សំពោច ចចក កញ្ជ្រោង និងថនិកសត្វផ្សេងទៀតក៏អាចចំលងជំងឺនេះមកមនុស្សបានដែរ។

## ២- តើអ្វីទៅជាវ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត?

វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួតត្រូវបានណែនាំអោយផ្តល់សម្រាប់អ្នកដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺនេះ និងជនរងគ្រោះដោយសត្វដែលសង្ស័យថាមានមេរោគឆ្កែឆ្កួតខាំ។

វ៉ាក់សាំងនេះត្រូវបានផលិតឡើងពីវីរុសឆ្កែឆ្កួតដែលត្រូវបានគេសំលាប់អោយងាប់ហើយ វាមិនអាចបង្កជាជំងឺឆ្កែឆ្កួតបានឡើយ។

## ៣- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួតនេះ? ហើយគួរធ្វើនៅពេលណា?

**ការផ្តល់វ៉ាក់សាំងបង្ការមុនមានសត្វខាំត្រូវបានណែនាំសំរាប់៖**

- អ្នកដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគនេះដូចជា ពេទ្យសត្វ អ្នកថែទាំសត្វ និងអ្នកដើររុកព្រៃ រឺបុគ្គលិកមន្ទីរពិសោធន៍ដែលប្រឈមនឹងមេរោគនេះ
- អ្នកដែលត្រូវធ្វើដំណើរទៅកាន់តំបន់ដែលកើតជំងឺនេះញឹកញាប់ ហើយអាចនឹងមានការប៉ះពាល់ជាមួយនឹងសត្វដែលផ្ទុកមេរោគនេះ

***** កាលវិភាគផ្តល់វ៉ាក់សាំងបង្ការមុនមានសត្វខាំគឺ៖ ថ្ងៃដំបូង - ៧ថ្ងៃក្រោយមក - ២៨ថ្ងៃក្រោយមក**

ក្រុមមនុស្សដែលមានការប្រឈមនឹងជំងឺនេះត្រូវនៅបន្តទទួលដូសទី៤ (១ឆ្នាំបន្ទាប់ពីដូសទី១) និងការរំលឹករៀងរាល់៥ឆ្នាំម្តងត្រូវបានគេអនុវត្ត។

***** កាលវិភាគផ្តល់វ៉ាក់សាំងជំងឺឆ្កែឆ្កួតក្រោយសត្វខាំគឺ៖ ថ្ងៃដំបូង - ថ្ងៃទី៣ - ថ្ងៃទី៧ - ថ្ងៃទី១៤ - ថ្ងៃទី២៨**

អ្នកដែលធ្លាប់ទទួលវ៉ាក់សាំងនេះពីមុនបានត្រឹមត្រូវរួចហើយនោះ ត្រូវទទួលវ៉ាក់សាំងបន្ថែម២ដូសទៀត ក្នុងករណីដែលមានសត្វខាំទៀតដោយ១ដូសត្រូវទទួលភ្លាមៗ រួច១ដូសបន្ទាប់ នៅ ៣ថ្ងៃក្រោយ។

## ៤- ពិភាក្សាជាមួយគ្រូពេទ្យ ប្រសិនបើ...

- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មជាមួយសមាសធាតុផ្សេងទៀតដែលមាននៅក្នុងវ៉ាក់សាំងនេះ
- អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ

**បើសិនជាអ្នកត្រូវបានសត្វខាំ អ្នកត្រូវតែទទួលវ៉ាក់សាំងបង្ការជាដាច់ខាត ទោះបីជាអ្នកកំពុងមានជំងឺអ្វីក៏ដោយ។**

## ៥- ផលវិបាកដែលអាចកើតមានក្រោយចាក់វ៉ាក់សាំង

ដូចឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឈឺក្បាល ឈឺសាច់ដុំ
- ឡើងកន្ទួលក្រហមលើស្បែក និងចង្អោរ
- ប្រតិកម្មធ្ងន់ធ្ងរ (កំរមានណាស់)

**ប្រសិនបើមានសញ្ញាប្រតកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**